សុន្ទរកថារបស់**ឯកឧត្តម គូម៉ាម៉ារូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់
ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

២៥ វិច្ឆិកា ២០១៣

**សូមគោរព លោក ហឿង ថុល ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិជើងព្រៃ ខេត្តកំពង់ចាម!**
**សូមគោរព លោក ស៊ូព្រីយ៉ានតូ ស៊ូព្រីយ៉ានតូ ប្រធានប្រចាំប្រទេស អង្គការភ្លែនអន្តរជាតិ-កម្ពុជា!**
**សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះ ខ្ញុំមាន សេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយចំនួន២សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។ ខ្ញុំសូមថ្លែងអំណរគុណហត្ថលេខី និងបុគ្គលិករបស់ស្រុកប្រតិបត្តិជើងព្រៃ និងអង្គការភ្លែនអន្តរជាតិ-កម្ពុជាដែលបានអញ្ជើញចូលរួមក្នុងពិធីនេះ។ ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងផងដែរ ដែលកិច្ចសន្យាផ្តល់ជំនួយទាំងនេះត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១៣ ដែលជាឆ្នាំខួបអនុស្សាវរីយ៍ទី ៦០ នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងទីមួយមានថវិកាសរុប១១៦ ៩៥០ដុល្លាអាមេរិកគឺដើម្បីសាងសង់អគារព្យាបាលជំងឺទូទៅ និងបំពាក់បរិក្ខារសុខាភិបាលដែលមានដូចជាគ្រែ និង កៅអីពេទ្យ ក្នុងមន្ទីរពេទ្យបង្អែកជើងព្រៃ ដែលនឹងអនុវត្តដោយការិយាល័យសុខាភិបាលស្រុកប្រតិបត្តិជើងព្រៃ ខេត្តកំពង់ចាម។ ខ្ញុំបានទទួលដំណឹងថាបច្ចុប្បន្ននេះមន្ទីរពេទ្យកំពុងខ្វះកន្លែងសម្រាប់ផ្តល់សេវាព្យាបាលជូនដល់អ្នកជំងឺ។យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ប្រមាណ២០០ ០០០នាក់ដោយការទទួលបានសេវាសុខាភិបាលប្រកបដោយគុណភាព។

គម្រោងទីពីរ មានថវិកាសរុប៧៥ ៥២៣ដុល្លាអាមេរិក គឺដើម្បីសាងសង់មណ្ឌលសុខភាពយុនរាម ក្នុងស្រុកបន្ទាយស្រី ខេត្តសៀមរាប ព្រមទាំងបំពាក់សម្ភារៈសុខាភិបាលរួមមានគ្រែ៩ និងមីក្រូទស្សន៍មួយដែលនឹងអនុវត្តគម្រោងដោយអង្គការភ្លែនអន្តរជាតិ-កម្ពុជា។ ខ្ញុំទទួលស្គាល់ថាចំនួនមណ្ឌលសុខភាពក្នុងស្រុកបន្ទាយស្រីមានកំណត់ដែលធ្វើឲ្យប្រជាជនមូលដ្ឋានត្រូវចំណាយពេលជាច្រើនម៉ោងក្នុងការធ្វើដំណើរទៅកាន់មណ្ឌលសុខភាព។ យើងរំពឹងថា ប្រជាជនក្នុងតំបន់ប្រមាណ៦ ៤០០នាក់នឹងទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ តាមរយៈការទទួលបានសេវាសុខភាពបឋមកាន់តែប្រសើរ។

គម្រោងទាំងពីរនេះត្រូវបានធ្វើឡើងដោយអនុលោមតាមគោលការណ៍ជាមូលដ្ឋាននៃជំនួយរបស់ជប៉ុនសម្រាប់កម្ពុជា និងស្របតាមទស្សនៈនៃការផ្តល់ជំនួយដើម្បីលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះផងដែរ។ វិស័យសុខាភិបាលគឺជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពជាច្រើនទៀតនៃជំនួយរបស់ជប៉ុនសម្រាប់កម្ពុជា ហើយដែលរដ្ឋាភិបាលជប៉ុនបាននិងកំពុងអនុវត្តគម្រោងជាច្រើនរួមមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងកិច្ចសហប្រតិបត្តិការបច្ចេកទេសជាដើម។

ខ្ញុំសង្ឃឹមថា គម្រោងទាំងពីរនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និងប្រកបដោយប្រសិទ្ធភាពដោយដៃគូរបស់យើងគឺស្រុកប្រតិបត្តិជើងព្រៃក្នុងខេត្តកំពង់ចាម និងអង្គការភ្លែនអន្តរជាតិ-កម្ពុជា ព្រមទាំងថែទាំយ៉ាងត្រឹមត្រូវដើម្បីលើកស្ទួយសេវាថែទាំសុខភាពក្នុងតំបន់គោលដៅនៃគម្រោងទាំងពីរនេះ។

ជាចុងក្រោយនេះ ខ្ញុំស ង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ សូមអរគុណ!